**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

បពិត្រ **ព្រះករុណា** ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តម នៃទិវាខួប ១៥ ឆ្នាំ ការឡើងគ្រងព្រះបរមសិរីរាជ្យសម្បត្តិ របស់ព្រះករុណាថ្លៃវិសេស ជាបឋមទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវសមានចិត្តអបអរសាទរសោមនស្សរីករាយក្រាបបង្គំថ្វាយព្រះពរ បវរសួស្តីសិរីវឌ្ឍនាមហាប្រសើរ សូមព្រះករុណាថ្លៃវិសេស ទ្រង់ស្តេចព្រះប្រកបដោយព្រះរាជសុខភាពល្អពេញបរិបូរណ៍ ព្រះពលានុភាពមាំមួនខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លាវាងវៃ ព្រះជន្មាទីឃាយុយឺនយូរដល់រយព្រះវស្សា ដើម្បីទ្រង់ស្តេចគង់ប្រថាប់ជាម្លប់ដល់ប្រជាពលរដ្ឋ ជាមីង មា បង ប្អូន កូនចៅ ជនរួមជាតិរបស់ព្រះអង្គជ្រកកោនត្រជាក់ត្រជុំ សុខដុមរមនាជាភិយ្យោភាពជារបៀងទៅ ។

ក្នុងព្រះបរមរាជវរោកាសដ៏វិសេសវិសុទ្ធថ្លៃថ្លាមហាប្រសើរនេះដែរ ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមលំឱនកាយថ្លែងនូវព្រះសម្ភារកថាស្ញប់ស្ញែងជ្រាលជ្រៅជាអតិបរមា ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្ចកាលទ្រង់ស្តេចបំពេញព្រះរាជបុជនិយកិច្ចដ៏ខ្ជាប់ខ្ជួន សព្វព្រះរាជហឫទ័យប្រោសប្រទាននូវព្រះព្រហ្មវិហារធម៌ ព្រះទសពិធរាជធម៌ ព្រមទាំងព្រះមនុស្សធម៌ដ៏ល្អផូរផង់ដើម្បីចម្រើនភាពកក់ក្តៅក្នុងជីវភាព និងសេចក្តីសុខក្សេមក្សាន្ត របស់ប្រជានុរាស្ត្រ ទូទាំងព្រះរាជាណាចក្រកម្ពុជាជារៀងរហូត ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមវន្ទាឧទ្ទិសដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកជាអាទិ៍ ព្រះគុណានុភាពអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ពិសេសដួងព្រះវិញ្ញាណក្ខន្ធ សម្តេចព្រះវររាជបិតាឯករាជ្យជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមប្រោសប្រទានព្រះពរប្រោះព្រំថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ស្តេចព្រះប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺៈ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **ព្រះករុណា** ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្តេចទទួលនូវអភិវន្ទនកិច្ច និងកតញ្ញូ កតវេទិតាដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំនិងភរិយា ។

*ថ្ងៃ អង្គារ ១៤រោច ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ តុលា ឆ្នាំ ២០១៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**